ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៨២ សហវ.ប្រក.ររលស

# ប្រកាស
# ស្តីពី
# ប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

# ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/ រកម/ ០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- អនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាក្នុងកិច្ចលទ្ធកម្មសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១._

ប្រកាសនេះ កំណត់អំពីនីតិវិធីនៃការកក់និងការដកប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ដើម្បីរួមចំណែកធានានូវប្រសិទ្ធភាពនៃការដេញថ្លៃ និងការអនុវត្តកិច្ចសន្យាលទ្ធកម្ម។

### ប្រការ២._

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់វិធីសាស្ត្រលទ្ធកម្ម លើកលែងតែៈ

- វិធីសាស្ត្រស្ទង់តម្លៃ វិធីសាស្ត្រជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន និងវិធីសាស្ត្រលទ្ធកម្មដោយឡែក ដែលមិនតម្រូវឱ្យកក់ប្រាក់ធានាការដេញថ្លៃ
- វិធីសាស្ត្រស្ទង់តម្លៃ វិធីសាស្ត្រជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន និងវិធីសាស្ត្រលទ្ធកម្មដោយឡែកសម្រាប់ការចុះកិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ និងការចុះកិច្ចសន្យាជាមួយនឹងសហគមន៍ ដែលមិនតម្រូវឱ្យកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា។

**ប្រការ៣.-**

និយមន័យនៃបច្ចេកសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

- **ប្រាក់កក់ធានាការដេញថ្លៃ** សំដៅដល់ប្រាក់កក់ដែលអ្នកដេញថ្លៃកក់នៅអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីចូលរួមការដេញថ្លៃ។
- **ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា** សំដៅដល់ប្រាក់កក់ដែលអ្នកដេញថ្លៃឈ្នះកក់នៅអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីទទួលបានលិខិតស្ដីពីការអញ្ជើញចុះកិច្ចសន្យា ដើម្បីធានាការអនុវត្តកិច្ចសន្យាមុនដំណើរការចុះកិច្ចសន្យាលទ្ធកម្ម។
- **លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ** សំដៅដល់លិខិតធានាដែលចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅពេលដែលអ្នកដេញថ្លៃបានកក់ ដើម្បីភ្ជាប់ជាមួយឯកសារស្នើដេញថ្លៃ។
- **លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា** សំដៅដល់លិខិតធានាដែលចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅពេលដែលអ្នកដេញថ្លៃឈ្នះបានកក់ ដើម្បីធានាការអនុវត្តកិច្ចសន្យា។

# ជំពូកទី២
# បែបបទនិងនីតិវិធីនៃការកក់
# ប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

## ផ្នែកទី១
## ប្រាក់កក់ធានាការដេញថ្លៃ

**ប្រការ៤.-**

ប្រាក់កក់ធានាការដេញថ្លៃ ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងសេចក្ដីណែនាំចំពោះអ្នកដេញថ្លៃ។ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវគណនាចំនួនប្រាក់កក់ធានាការដេញថ្លៃក្នុងអត្រា ២(ពីរ)ភាគរយ នៃទឹកប្រាក់ជានាចំណាយដោយបង្កើនបង្គ្រប់ជាចំនួនគត់ខ្ទង់រយ។

**ប្រការ៥.-**

អ្នកដេញថ្លៃ អាចកក់ប្រាក់កក់ធានាការដេញថ្លៃចូលគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ដែលបើកនៅធនាគារជាតិនៃកម្ពុជា/ធនាគារពាណិជ្ជដៃគូ ឬអ្នកដេញថ្លៃ អាចកក់ប្រាក់កក់ធានាការដេញថ្លៃ នៅធនាគារពាណិជ្ជដៃគូណាមួយដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦.-**

អគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ តាមគំរូកំណត់ក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

**ប្រការ៧.-**

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ត្រូវមានសុពលភាព ៣០(សាមសិប)ថ្ងៃ យ៉ាងតិច ក្រោយផុតសុពលភាពនៃឯកសារស្នើដេញថ្លៃ។ ក្នុងករណីមានការពន្យារពេលសុពលភាពនៃឯកសារស្នើដេញថ្លៃនោះសុពលភាពនៃលិខិតធានាប្រាក់កក់ធានាការដេញថ្លៃក៏ត្រូវបានពន្យារពេលស្របគ្នាដែរ។

**ប្រការ៨.-**

អ្នកដេញថ្លៃ ត្រូវភ្ជាប់ជាមួយឯកសារស្នើដេញថ្លៃនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ។ សំណុំឯកសារស្នើដេញថ្លៃណាដែលមិនមានភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ឬមានលិខិតធានាប្រាក់កក់ធានាការដេញថ្លៃដែលមានទឹកប្រាក់តិចជាងចំនួនទឹកប្រាក់ ដែលបានកំណត់នៅក្នុងឯកសារដេញថ្លៃនឹងត្រូវបានបដិសេធ។

**ប្រការ៩.-**

ប្រាក់កក់ធានាការដេញថ្លៃ នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋប្រសិនបើ៖

- អ្នកដេញថ្លៃសុំដកសំណុំឯកសារស្នើដេញថ្លៃរបស់ខ្លួនវិញក្នុងសុពលភាពនៃឯកសារស្នើដេញថ្លៃ
- អ្នកដេញថ្លៃឈ្នះមិនព្រមផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- អ្នកដេញថ្លៃឈ្នះមិនព្រមចុះកិច្ចសន្យាក្នុងរយៈពេលដែលបានកំណត់ក្នុងលិខិតស្តីពីការអញ្ជើញចុះកិច្ចសន្យា។

ករណីមានការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ៖

- ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចេញលិខិតស្តីពីការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ (ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ) ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបង្វែរប្រាក់កក់ធានាការដេញថ្លៃនោះចូលថវិការដ្ឋតាមរយៈគណនីទោលរតនាគារ
- ចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាសហគ្រាសសាធារណៈនិងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចេញលិខិតស្តីពីការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ (ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ) ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបង្វែរប្រាក់កក់ធានាការដេញថ្លៃចូលគណនីរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម។



៤១២

**ប្រការ១០.-**

ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីអ្នកដេញថ្លៃឈ្នះប្រគល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានិងបានចុះកិច្ចសន្យារួច ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញលិខិតស្តីពីការដកប្រាក់កក់ធានាការដេញថ្លៃ (ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ៣ នៃប្រកាសនេះ) ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបង្វែរប្រាក់កក់ធានាការដេញថ្លៃជូនគ្រប់អ្នកដេញថ្លៃវិញ និងត្រូវចម្លងលិខិតនោះជូនអ្នកដេញថ្លៃ។

## ផ្នែកទី២
## ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

**ប្រការ១១.-**

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវមានចំនួនស្មើនឹង ១០(ដប់)ភាគរយ នៃតម្លៃចុះកិច្ចសន្យា។

ការគណនាចំនួនប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវបង្កើនបង្គ្រប់ជាលេខគត់ខ្ទង់រយ។

**ប្រការ១២.-**

អ្នកដេញថ្លៃឈ្នះ អាចកក់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាចូលគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ដែលបើកនៅធនាគារជាតិនៃកម្ពុជា/ធនាគារពាណិជ្ជដៃគូ ឬអ្នកដេញថ្លៃឈ្នះ អាចកក់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានៅធនាគារពាណិជ្ជដៃគូណាមួយដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១៣.-**

អគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា តាមគំរូកំណត់ក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។

**ប្រការ១៤.-**

លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា សម្រាប់កិច្ចសន្យាទំនិញនិងសេវាកម្ម ត្រូវមានសុពលភាពរហូតដល់ការប្រគល់ទទួលចប់ជាស្ថាពរ។ ចំពោះ កិច្ចសន្យាសំណង់ ត្រូវមានសុពលភាពរហូតដល់ការប្រគល់ទទួលចប់សុពលភាពធានាគុណភាពសំណង់។

**ប្រការ១៥.-**

ក្នុងរយៈពេល ១០(ដប់)ថ្ងៃ យ៉ាងយូរបន្ទាប់ពីស្ថាប័នអនុវត្តលទ្ធកម្មចេញលិខិតស្តីពីការអញ្ជើញចុះកិច្ចសន្យា អ្នកដេញថ្លៃឈ្នះត្រូវផ្តល់នូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។ ការខកខានរបស់អ្នកដេញថ្លៃឈ្នះក្នុងការផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការចាត់ទុកជាមោឃៈនៃការសម្រេចប្រគល់កិច្ចសន្យា។

**ប្រការ១៦.-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវនូវចំនួនទឹកប្រាក់ដែលអ្នកដេញថ្លៃឈ្នះបានកក់ និងទម្រង់នៃលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដែលចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុននឹងដំណើរការចុះកិច្ចសន្យា។

**ប្រការ១៧.-**

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ប្រសិនបើអ្នកដេញថ្លៃឈ្នះបដិសេធការអនុវត្តកិច្ចសន្យាដែលបានចូលជាធរមានឬបំពានលក្ខខណ្ឌកិច្ចសន្យា និងត្រូវបានស្ថាប័នអនុវត្តលទ្ធកម្មបញ្ឈប់កិច្ចសន្យាមុនកាលកំណត់។

ករណីមានការរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា៖

- ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចេញលិខិតស្ដីពីការរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ៥ នៃប្រកាសនេះ) ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបង្វែរប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានោះចូលថវិការដ្ឋតាមរយៈគណនីទោលរតនាគារ
- ចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាសហគ្រាសសាធារណៈនិងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចេញលិខិតស្ដីពីការរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា(ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ៥ នៃប្រកាសនេះ) ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបង្វែរប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានោះចូលគណនីផ្ទាល់របស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម។

**ប្រការ១៨.-**

ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីប្រគល់ទទួលទំនិញនិងសេវាកម្មចប់ជាស្ថាពរ ឬ បន្ទាប់ពីប្រគល់ទទួលចប់សុពលភាពធានាគុណភាពសំណង់ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញលិខិតស្ដីពីការដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ៦ នៃប្រកាសនេះ) ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវចម្លងលិខិតនោះជូនអ្នកផ្គត់ផ្គង់/អ្នកទទួលការ ដើម្បីដកប្រាក់កក់វិញ។

**ប្រការ១៩.-**

តារាងឈ្មោះធនាគារពាណិជ្ជដៃគូ ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាឧបសម្ព័ន្ធ៧ នៃប្រកាសនេះ និងដែលជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់។

## ជំពូកទី៣
## បទប្បញ្ញត្តិដោយឡែកសម្រាប់
## ស្ថាប័នអនុវត្តលទ្ធកម្មដែលជាសហគ្រាសសាធារណៈ

**ប្រការ២០.-**

ចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាសហគ្រាសសាធារណៈ អាចអនុញ្ញាតឱ្យទទួលប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ជាមូលប្បទានប័ណ្ណបញ្ជាក់ (Certified Cheque) ចេញដោយធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចបន្ធូរបន្ថយ ឬលើកលែង លក្ខខណ្ឌប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា តាមការស្នើសុំរបស់សហគ្រាសសាធារណៈ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ២២.-**

ប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា និងសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃ និងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាក្នុងកិច្ចលទ្ធកម្មសាធារណៈ ត្រូវទុកជានិរាករណ៍។

**ប្រការ២៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ
- ដូចប្រការ ២៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ..(បំពេញឈ្មោះ)....**

**លិខិតធានា**
**ប្រាក់កក់ធានាការដេញថ្លៃ**
**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម......**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ........................................... មានបំណងដាក់សំណុំឯកសារស្នើដេញថ្លៃដើម្បីធ្វើការផ្គត់ផ្គង់/សាងសង់/ជួសជុល/សេវា.................................... ដែលត្រូវបើកឯកសារស្នើដេញថ្លៃនៅថ្ងៃទី......... ខែ........ឆ្នាំ...................។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ ................... សូមធានាចំពោះមុខប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម............................................. នូវប្រាក់កក់ធានាការដេញថ្លៃចំនួន .................................. (សរសេរជាអក្សរ....................................)។

ក្នុងករណីមានលក្ខខណ្ឌណាមួយកើតមានឡើងក្នុងចំណោមលក្ខខណ្ឌទាំងបីខាងក្រោម ៖

១- ប្រសិនបើអ្នកដេញថ្លៃ ដកសំណុំឯកសារស្នើដេញថ្លៃរបស់ខ្លួនវិញក្នុងសុពលភាពនៃឯកសារស្នើដេញថ្លៃ

២- ប្រសិនបើអ្នកដេញថ្លៃ មិនព្រមកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា

៣- ប្រសិនបើអ្នកដេញថ្លៃ បដិសេធការចុះហត្ថលេខាលើកិច្ចសន្យា ក្នុងសុពលភាពនៃឯកសារស្នើដេញថ្លៃ

នោះអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ ............ នឹងធ្វើការរឹបអូសបង់ចូលថវិការដ្ឋនូវចំនួនប្រាក់កក់ខាងលើ នៅពេលដែលបានទទួលលិខិតស្នើសុំពីប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម.............. ដែលបញ្ជាក់ថាអ្នកដេញថ្លៃមិនគោរពតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងបីខាងលើ។

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាពរយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ ក្រោយសុពលភាពឯកសារស្នើដេញថ្លៃ។

ថ្ងៃ.........................ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២៥.....
............... ថ្ងៃទី....... ខែ.......... ឆ្នាំ២០......

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត**
**/ធនាគារពាណិជ្ជ**

ឧបសម្ព័ន្ធ២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថាប័នអនុវត្តលទ្ធកម្ម**......

**លិខិតស្ដីពី**
**ការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ**
**សូមគោរពជូន**
**ឯកឧត្តមអគ្គនាយករតនាគារជាតិ /លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/**
**ធនាគារពាណិជ្ជ**......

**កម្មវត្ថុ៖** ការស្នើសុំរឹបអូសប្រាក់កក់ធានាការដេញថ្លៃស្ដីពី...........របស់ក្រុមហ៊ុន/សហគ្រាស..........។

**យោង៖** លិខិតធានាប្រាក់កក់ធានាកាដេញថ្លៃលេខ........ចុះថ្ងៃទី......ខែ.........ឆ្នាំ២០..... របស់អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ...........។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ**........... មេត្តាជ្រាបថា ក្រុមហ៊ុន/សហគ្រាស............ បានដកសំណុំឯកសារស្នើដេញថ្លៃរបស់ខ្លួនវិញក្នុងសុពលភាពនៃឯកសារស្នើដេញថ្លៃ/ មិនព្រមផ្ដល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា/ មិនព្រមចុះកិច្ចសន្យាក្នុងរយៈពេលដែលបានកំណត់ក្នុងលិខិតស្ដីពីការអញ្ជើញចុះកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ**.......មេត្តាបង្វែរប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួន........... ចូលគណនីលេខ.............. របស់...................តាមការគួរ។

សូម **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ**.... មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃ.........................ខែ........... ឆ្នាំ.... ....ស័ក ព.ស.២៥.....
................ ថ្ងៃទី....... ខែ........... ឆ្នាំ២០......
**ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម**

ចម្លងជូន៖
-ក្រុមហ៊ុន/សហគ្រាស
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថាប័នអនុវត្តលទ្ធកម្ម**......

**លិខិតស្តីពី**
**ការដកប្រាក់កក់ធានាការដេញថ្លៃ**
**សូមគោរពជូន**
**ឯកឧត្តមអគ្គនាយករតនាគារជាតិ /លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/**
**ធនាគារពាណិជ្ជ**.........

**កម្មវត្ថុ÷** ការស្នើសុំបង្វែរប្រាក់កក់ធានាការដេញថ្លៃស្តីពី................ជូនក្រុមហ៊ុន/សហគ្រាស.......។

**យោង÷** លិខិតធានាប្រាក់កក់ធានាការដេញថ្លៃលេខ........ចុះថ្ងៃទី......ខែ.........ឆ្នាំ....... របស់អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ...........។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន**ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ......** មេត្តាជ្រាបថា គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម បានវាយតម្លៃនិងជ្រើសរើសក្រុមហ៊ុន/សហគ្រាស........ជាអ្នកដេញថ្លៃឈ្នះ ហើយក្រុមហ៊ុន/សហគ្រាស................ ជាអ្នកដេញថ្លៃឈ្នះ ហើយក្រុមហ៊ុន/សហគ្រាស........បានចុះកិច្ចសន្យាស្តីពី.............រួចហើយ។

អាស្រ័យហេតុនេះសូម **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ............** មេត្តាបង្វែរប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួន...........................ជូនក្រុមហ៊ុន/សហគ្រាស.............. វិញតាមការគួរ។

សូម **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ**....... មេត្តាទទួលនូវ ការគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃ.........................ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២៥.....
................ ថ្ងៃទី....... ខែ.......... ឆ្នាំ២០......
**ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម**

ចម្លងជូន:
-ក្រុមហ៊ុន/សហគ្រាស..........'ដើម្បីទៅដកប្រាក់កក់"
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ**...(បំពេញឈ្មោះ)...

**លិខិតធានា**
**ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**
**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម**......

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ....................................... បានទទួលលិខិតស្តីពីការចុះកិច្ចសន្យាការផ្គត់ផ្គង់/សាងសង់/ជួសជុល/សេវា...................... លេខ.............ចុះថ្ងៃទី....... ខែ........ឆ្នាំ..............ដែលមានតម្លៃកិច្ចសន្យាចំនួន..................................(សរសេរជាអក្សរ.........................................)។

ដោយមានចែងនៅក្នុងលិខិតស្តីពីការចុះកិច្ចសន្យា **អ្នកផ្គត់ផ្គង់/អ្នកទទួលការ** ត្រូវផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ.......... ដែលមានតម្លៃទឹកប្រាក់ស្មើនឹង ១០(ដប់)ភាគរយ នៃតម្លៃកិច្ចសន្យា ដើម្បីធានាការអនុវត្តកាតព្វកិច្ចស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ ................................ សូមធានា និងទទួលខុសត្រូវ នូវប្រាក់កក់ចំនួន ....................................... (សរសេរជាអក្សរ.......................................)។

ប្រាក់កក់ខាងលើនេះ នឹងត្រូវរឹបអូសបង់ចូលថវិកាជាតិ នៅពេលបានទទួលលិខិតស្នើសុំពី **អ្នកទិញ/អ្នកម្ចាស់ការ** ដែលបញ្ជាក់ថា **អ្នកផ្គត់ផ្គង់/អ្នកទទួលការ** មិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន/សហគ្រាស គ្មានសិទ្ធិប្រកែក ឬតវ៉ាឡើយ។

លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា សម្រាប់កិច្ចសន្យាទំនិញនិងសេវាកម្ម ត្រូវមានសុពលភាពរហូតដល់ការប្រគល់ទទួលចប់ជាស្ថាពរ។ ចំពោះ កិច្ចសន្យាសំណង់ ត្រូវមានសុពលភាពរហូតដល់ការប្រគល់ទទួលចប់សុពលភាពធានាគុណភាពសំណង់។

ថ្ងៃ.........................ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២៥.....
............... ថ្ងៃទី....... ខែ.......... ឆ្នាំ២០......
**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត**
**/ធនាគារពាណិជ្ជ**

ឧបសម្ព័ន្ធ៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថាប័នអនុវត្តលទ្ធកម្ម**......

**លិខិតស្តីពី**
**ការរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**
**សូមគោរពជូន**
**ឯកឧត្តមអគ្គនាយករតនាគារជាតិ /លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ** ......

**កម្មវត្ថុ ÷** ការស្នើសុំរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាស្តីពី...............របស់ក្រុមហ៊ុន/សហគ្រាស......។

**យោង ÷** លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាលេខ......ចុះថ្ងៃទី............ខែ...........ឆ្នាំ២០....... របស់អគ្គនាយដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ...........។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ.........** មេត្តាជ្រាបថា ក្រុមហ៊ុន/សហគ្រាស............មិនបានបំពេញកាតព្វកិច្ចត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាលេខ............... ចុះថ្ងៃទី......ខែ........ឆ្នាំ២០...... ស្តីពី............ ហើយត្រូវបាន.....(បញ្ចូលឈ្មោះស្ថាប័នអនុវត្តលទ្ធកម្ម)...... បញ្ចប់កិច្ចសន្យានេះជាស្ថាពររួចហើយ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ..............** មេត្តាបង្វែរប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដែលមានចំនួន..............ចូលគណនីលេខ...................... របស់............................តាមការគួរ។

សូម **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ......** មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃ..........................ខែ........... ឆ្នាំ.... ....ស័ក ព.ស.២៥.....
................ ថ្ងៃទី....... ខែ........... ឆ្នាំ២០......
**ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម**

ចម្លងជូនៈ
-ក្រុមហ៊ុន/សហគ្រាស
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថាប័នអនុវត្តលទ្ធកម្ម**......

**លិខិតស្តីពី**
**ការដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**
**សូមគោរពជូន**
**ឯកឧត្តមអគ្គនាយករតនាគារជាតិ /លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ ធនាគារពាណិជ្ជ**.........

**កម្មវត្ថុ ÷** ការស្នើសុំបង្វែរប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាស្តីពី.................ជូនក្រុមហ៊ុន/សហគ្រាស.......។

**យោង ÷** លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា លេខ............... ចុះថ្ងៃទី.........ខែ...........ឆ្នាំ២០....... របស់អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ...........។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ.................** មេត្តាជ្រាបថា ក្រុមហ៊ុន/សហគ្រាស........... បានបំពេញកាតព្វកិច្ចចប់សព្វគ្រប់ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាស្តីពី.............លេខ..........ចុះថ្ងៃទី.......ខែ..........ឆ្នាំ........។

អាស្រ័យហេតុនេះសូម **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ ធនាគារពាណិជ្ជ..........** មេត្តាបង្វែរប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដែលមានចំនួន.....................ជូនក្រុមហ៊ុន/ សហគ្រាស..........វិញតាមការគួរ។

សូម **ឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត/ធនាគារពាណិជ្ជ .......** មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃ..........................ខែ........... ឆ្នាំ.... ....ស័ក ព.ស.២៥.....
................ ថ្ងៃទី....... ខែ........... ឆ្នាំ២០......
**ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម**

ចម្លងជូនៈ
-ក្រុមហ៊ុន/សហគ្រាស..........“ដើម្បីទៅដកប្រាក់កក់”
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ៧

# តារាងឈ្មោះធនាគារពាណិជ្ជដៃគូ
# ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | ឈ្មោះធនាគារ |
|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ២ | ធនាគារ វីង (ខេមបូឌា) ម.ក |
| ៣ | ធនាគារ កាណាឌីយ៉ា ក.អ |
| ៤ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា |
| ៥ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី |
| ៦ | ធនាគារ វឌ្ឍនៈ |
| ៧ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) |
| ៨ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី |
| ៩ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ១០ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ |
| ១១ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក |
| ១២ | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) |
| ១៣ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ១៤ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី |
| ១៥ | ធនាគារ ព្រីនស៍ ម.ក |
| ១៦ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ១៧ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក |
| ១៨ | ធនាគារ ហត្ថា ម.ក |
| ១៩ | ធនាគារ សហពាណិជ្ជ ក.អ |
| ២០ | ធនាគារ អ៊ឹមប៊ី (ខេមបូឌា) ម.ក |
| ២១ | ធនាគារ ហ្វីលីព ភីអិលស៊ី |

**កំណត់សម្គាល់:**

បច្ចុប្បន្នភាពត្រឹមខែ.វិច្ឆិកា... ឆ្នាំ.២០២៥